ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
ការិយាល័យអ្នកនាំពាក្យ

# ខ្លឹមសារសង្ខេបសម្រាប់អ្នកសារព័ត៌មាន

## ដោយ ឯកឧត្តម នង សាកល អ្នកនាំពាក្យស្តីទីនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

(ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០២៥)

*សូមគោរព និងជម្រាបសួរបងប្អូន ជនរួមជាតិ និងអ្នកសារព័ត៌មានជាតិនិងអន្តរជាតិ ទាំងអស់!*

ខ្ញុំសូមយកឱកាសនេះ ជម្រាបជូនអំពីបច្ចុប្បន្នភាពនៃកិច្ចខិតខំប្រឹងប្រែងការទូតដែលកម្ពុជាកំពុងបន្តធ្វើដើម្បីដោះស្រាយស្ថានការណ៍តាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងបញ្ជាក់អំពីការពិតមួយចំនួនទាក់ទងនឹងការវិវត្តនៃសភាពការណ៍នាពេលថ្មីៗនេះ ដូចខាងក្រោម៖

**១) កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបញ្ចប់បញ្ហាព្រំដែនជាមួយថៃ៖**

- ដូចដែលបងប្អូនបានដឹងហើយ គឺថ្ងៃទី ៩ និង ១១ ខែធ្នូ ឆ្នាំ ២០២៥ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃកម្ពុជា បានសន្ទនាតាមទូរស័ព្ទជាមួយឯកឧត្តម អាន់វ៉ា អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រីម៉ាឡេស៊ី។ នៅថ្ងៃទី១២ ខែធ្នូ **សម្តេចធិបតី** ក៏បានសន្ទនាតាមទូរស័ព្ទជាមួយឯកឧត្តម ប្រធានាធិបតីអាម៉េរិក ដូណាល់ ត្រាំ ដែលបានធ្វើតាមការលើកឡើងជាសាធារណៈរបស់ឯកឧត្តមថានឹងទូរស័ព្ទមកពិភាក្សាជាមួយថ្នាក់ដឹកនាំនៃប្រទេសទាំងពីរដើម្បីបញ្ចប់ការប្រយុទ្ធគ្នា។ **សម្តេចធិបតី ហ៊ុន ម៉ាណែត** បានថ្លែងអំណរគុណថ្នាក់ដឹកនាំទាំងពីរ ចំពោះការខិតខំប្រឹងប្រែងជាបន្តបន្ទាប់សំដៅសម្រេចឱ្យបាននូវសន្តិភាពយូរអង្វែងរវាងកម្ពុជា-ថៃ និងបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី។ លើសពីនេះ **សម្តេច** បានយល់ព្រមចំពោះបទឈប់បាញ់ដែលបានស្នើឡើងក្នុងអំឡុងពេលនៃការពិភាក្សាតាមទូរស័ព្ទ ហើយក៏បានអំពាវនាវឱ្យមានការវិលត្រឡប់ទៅអនុវត្តសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួវិញ។
  - ⇒ នាយករដ្ឋមន្ត្រីម៉ាឡេស៊ី បានបង្ហោះសារនៅលើទំព័រហ្វេសប៊ុកឯកឧត្តម ដោយជំរុញឱ្យភាគីទាំងពីរបញ្ឈប់រាល់ទម្រង់អរិភាព ជៀសវាងសកម្មភាពយោធាលើសពីនេះទៀត រួមទាំងការប្រើប្រាស់កម្លាំង ឬការចល័តអង្គភាពប្រដាប់អាវុធ ដោយចាប់ផ្តើមពីម៉ោង១០ យប់ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥។ ដើម្បីតម្លាភាព ក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT) ត្រូវបានស្នើឱ្យដាក់ពង្រាយ ហើយបេសកកម្ម AOT នឹងត្រូវបានគាំទ្រដោយការត្រួតពិនិត្យនៃផ្កាយរណបដែលមានការបញ្ជាក់ដោយម៉ាឡេស៊ី និងសហរដ្ឋអាមេរិក។ លទ្ធផលពីការត្រួតពិនិត្យផ្កាយរណបនឹងត្រូវបង្ហាញនៅក្នុងកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ាន (AMM) ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០២៥។ រដ្ឋមន្ត្រីការបរទេស

កម្ពុជាបានយល់ព្រមចូលរួមកិច្ចប្រជុំនេះ។ រដ្ឋមន្ត្រីការបរទេសថៃក៏បានយល់ព្រមចូលរួមកិច្ចប្រជុំនេះតាមការស្នើ ប៉ុន្តែឥឡូវបានស្នើសុំឱ្យពន្យារពេលទៅថ្ងៃក្រោយវិញ។

⇒ ឆ្លើយតបទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់នាយករដ្ឋមន្ត្រីម៉ាឡេស៊ី ក្នុងការសម្របសម្រួលឱ្យមានបទឈប់បាញ់ចាប់តាំងពីថ្ងៃទី៩ ខែធ្នូ និងរបស់ឯកឧត្តមប្រធានាធិបតី ដូណាល់ ត្រាំ នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេសថៃបានប្រកាសថា ទ្វារសម្រាប់ការចរចាជាមួយកម្ពុជាត្រូវបានបិទ ហើយប្រទេសថៃមិនទាន់ត្រៀមខ្លួនសម្រាប់ការចរចាសន្តិភាពនៅឡើយទេ។ នៅថ្ងៃទី១៤ ខែធ្នូ នាយករដ្ឋមន្ត្រីថៃបាននិយាយថា «**មិនមានកិច្ចព្រមព្រៀងបទឈប់បាញ់ទេ**»។

⇒ ស្រាប់តែនៅព្រឹកព្រលឹម ថ្ងៃទី១៤ ខែធ្នូ យន្តហោះចម្បាំងថៃ បានទម្លាក់គ្រាប់បែកបំផ្លាញស្ពានជ័យជំនះមួយ ស្ថិតនៅចម្ងាយជ្រៅក្នុងដែនអធិបតេយ្យកម្ពុជា។

⇒ **ចំពោះ «ការមួលបង្កាច់ និងការអធិប្បាយនានា»៖** ភាគីថៃ អះអាងថា នាយករដ្ឋមន្ត្រីម៉ាឡេស៊ី **«មិនបានលើកឡើងសោះឡើយអំពីបទឈប់បាញ់»** ហើយថា កម្ពុជាបានអធិប្បាយ **«បំភាន់ការពិត»**។

- **តែជាការពិត** គឺនៅក្នុងការសន្ទនាតាមទូរស័ព្ទ នៅថ្ងៃទី១១ ខែធ្នូ សម្តេចធិបតី ហ៊ុន ម៉ាណែត និងនាយករដ្ឋមន្ត្រី អាន់វ៉ា អ៊ីប្រាហ៊ីម បានពិភាក្សាអំពីភាពចាំបាច់បន្ទាន់ក្នុងការបញ្ឈប់អរិភាព ដែល សម្តេចធិបតីនាយករដ្ឋមន្ត្រី បានស្វាគមន៍ជាផ្លូវការចំពោះគំនិតផ្តួចផ្តើមនេះ។ សម្រាប់កម្ពុជា យើងយល់ថា បទឈប់បាញ់មួយត្រូវបានស្នើឡើងហើយនៅយប់នោះ។
- សច្ចភាពសាមញ្ញមួយដែលថានោះជា «បទឈប់បាញ់» ឬ «ការបញ្ឈប់ការបង្កហេតុ» ដោយភាគីទាំងពីរក៏ដោយ ចេតនាគឺសំដៅស្តារសន្តិភាពឡើងវិញ។ **កម្ពុជា បាននិយាយថា «យល់ព្រម» ចំណែក ថៃ បានឆ្លើយថា «អត់ទេ»**។

## ២). ការអំពាវនាវឱ្យមានការបន្ធូរបន្ថយភាពតានតឹង និងការវិលត្រឡប់ទៅរកការសន្ទនាវិញ

- កម្ពុជា បានកត់សម្គាល់ថាមាន ប្រទេសម៉ាឡេស៊ី ព្រមជាមួយរដ្ឋសមាជិកអាស៊ានផ្សេងទៀត សហរដ្ឋអាមេរិក ចិន បារាំង កាណាដា កូរ៉េខាងត្បូង អគ្គលេខាធិការអង្គការសហប្រជាជាតិ និងសហភាពអឺរ៉ុប ក្នុងចំណោមប្រទេស/តួអង្គផ្សេងៗទៀត បានអំពាវនាវឱ្យកម្ពុជា និងថៃ ប្រកាន់យកការអត់ធ្មត់ ការពារជនស៊ីវិល និងវិលត្រឡប់មករកការចរចាវិញ ដើម្បីដោះស្រាយជម្លោះព្រំដែនដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងដែលមានស្រាប់ រួមទាំងសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួផង។

- កម្ពុជាសូមថ្លែងអំណរគុណចំពោះការអំពាវនាវឱ្យត្រឡប់មករកមាគ៌ាសន្តិភាពវិញ ហើយនៅតែប្តេជ្ញាចិត្តចំពោះការដោះស្រាយជម្លោះដោយសន្តិវិធីជាមួយប្រទេសថៃ ដោយស្មោះត្រង់ និងអនុលោមតាមច្បាប់អន្តរជាតិយ៉ាងពេញលេញ។ ហើយយើងក៏បានអំពាវនាវឱ្យមានការវិលត្រឡប់ទៅរកសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួវិញផងដែរ។

*បងប្អូន ជនរួមជាតិ និងអ្នកសារព័ត៌មានជាតិនិងអន្តរជាតិ ទាំងអស់!*

## ៣). ពាក់ព័ន្ធនឹងការខូចខាតផ្នែកមនុស្សធម៌ និងហេដ្ឋារចនាសម្ព័ន្ធ (ថ្ងៃទី៧-១៥ ខែធ្នូ)

- ថៃអះអាងថាសកម្មភាពរបស់ពួកគេគឺមានលក្ខណៈ «**សមាមាត្រ ឬការពារខ្លួន**»។ ការពិតជាក់ស្តែងបង្ហាញឱ្យឃើញផ្ទុយទៅវិញទេ។ ការវាយប្រហាររបស់កងកម្លាំងប្រដាប់អាវុធថៃមកលើប្រទេសកម្ពុជាតាមផ្លូវគោក អាកាស និងសមុទ្រជាមួយនឹងអាវុធគ្រប់ប្រភេទ និងគ្រប់កម្រិត គឺមិនមែនជាការការពារខ្លួនទាល់តែសោះ។ ការវាយប្រហារតាមអាកាស ការបាញ់ផ្លោងពីកងទ័ពជើងទឹកជាដើម បានបំផ្លាញទ្រព្យសម្បត្តិស៊ីវិល និងហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងខេត្តចំនួនប្រាំពីរ (ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កោះកុង និងសៀមរាប)។ សូម្បីប្រាសាទបុរាណ រួមទាំងប្រាសាទព្រះវិហារ ដែលជាបេតិកភណ្ឌពិភពលោក ផ្ទះសម្បែង ផ្លូវថ្នល់ និងស្ពាននានា ក៏គ្មានលើកលែងដែរ។ ថៃប្រើយន្តហោះចម្បាំង F-16 និង Gripen ទម្លាក់គ្រាប់បែកយ៉ាងសាហាវពាសលើតំបន់ស៊ីវិលក្នុងដែនអធិបតេយ្យកម្ពុជា។ នៅក្នុងការវាយប្រហារតាមអាកាសចុងក្រោយនេះ កងទ័ពអាកាសថៃបានទម្លាក់គ្រាប់បែកចូលជ្រៅរហូតដល់ ៧០ គ.ម ពីព្រំដែន ក្នុងខេត្តសៀមរាប។
- កម្ពុជាបានថ្កោលទោសទង្វើឈ្លានពានដោយអាវុធទាំងនេះ ដែលរំលោភបំពានលើដែនអធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា ព្រមទាំងធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញអាស៊ាន និងច្បាប់មនុស្សធម៌អន្តរជាតិផងដែរ។
- ទោះជាយ៉ាងនេះក្តី កម្ពុជានៅតែប្តេជ្ញាចិត្តចំពោះលក្ខខណ្ឌនៃបទឈប់បាញ់ និងសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ ក៏ដូចជាកិច្ចព្រមព្រៀងទាំងអស់ដែលសម្រេចបានក្រោមយន្តការទ្វេភាគីដែលមានស្រាប់ ដូចជា គណៈកម្មាធិការព្រំដែនទូទៅ (GBC) គណៈកម្មាធិការព្រំដែនថ្នាក់ឃោធភូមិភាគ (RBC) និង គណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោកកម្ពុជា (JBC)។

## ៤). អំពីកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសពិសេសអាស៊ាន

- កម្ពុជាសូមវាយតម្លៃខ្ពស់ចំពោះតួនាទីសកម្ម និងស្ថាបនារបស់ម៉ាឡេស៊ីក្នុងនាមជាប្រធានអាស៊ានក្នុងការដឹកនាំអាស៊ានពេញមួយឆ្នាំ២០២៥។
- យើងសូមស្វាគមន៍ចំពោះការជួយសម្របសម្រួលរបស់ប្រទេសម៉ាឡេស៊ីក្នុងការកោះប្រជុំកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ាន ដើម្បីពិភាក្សាអំពីស្ថានភាពបច្ចុប្បន្នរវាងកម្ពុជា និងថៃ។ ដំបូង

កិច្ចប្រជុំនេះត្រូវបានគ្រោងធ្វើនៅថ្ងៃទី ១៦ ខែធ្នូ ប៉ុន្តែឥឡូវនេះ កិច្ចប្រជុំត្រូវបានលើកពេលទៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥វិញ តាមការស្នើសុំរបស់ប្រទេសថៃ។ កម្ពុជារង់ចាំចូលរួមកិច្ចប្រជុំដ៏សំខាន់នេះ ហើយសង្ឃឹមថាកិច្ចប្រជុំនេះនឹងសម្រេចបានលទ្ធផលវិជ្ជមានដល់គ្រប់ភាគី។

***បងប្អូន ជនរួមជាតិ និងអ្នកសារព័ត៌មានជាតិនិងអន្តរជាតិ ទាំងអស់!***

**នៅទីបញ្ចប់នេះ**

- ខ្ញុំសូមបញ្ជាក់ម្តងទៀតថា កម្ពុជាសូមបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តដ៏មុឹងម៉ាត់ និងឥតងាករេរបស់ខ្លួនចំពោះការអនុវត្តបទឈប់បាញ់ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០២៥ និងសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ ថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២៥។
- ជាពិសេស បទឈប់បាញ់ត្រូវតែអនុវត្តយ៉ាងពេញលេញដោយភាគីទាំងពីរ ទាំងក្នុងសកម្មភាពជាក់ស្តែង និងដោយសុច្ឆន្ទៈ បន្តបិតបេះយូរអង្វែង និងគាំទ្រដោយយន្តការច្បាស់លាស់ដែលមានការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់ពីក្រុមអ្នកសង្កេតការអាស៊ាន។
- ខ្ញុំសូមបញ្ជាក់ថា អាទិភាពចម្បងបំផុតរបស់យើងគឺ ការស្តារសន្តិភាពឡើងវិញ និងការការពារជីវិតមនុស្សស្លូតត្រង់។ ហើយអាទិភាពបន្ទាន់គឺត្រូវបញ្ឈប់ការប្រយុទ្ធ និងជៀសវាងការធ្វើឱ្យស្ថានការណ៍មនុស្សធម៌កាន់តែអាក្រក់ទៅៗ សម្រាប់ភាគីទាំងពីរ។

សូមអរគុណ!